ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

# តាមនាមប្រជារាស្ត្រខ្មែរ

សំណុំរឿងរដ្ឋប្បវេណី
លេខ: ២៨៨
ចុះថ្ងៃទី ១១-៧-២០១៣
សាលដីកា
លេខ: ២០ក្រ/VH
ចុះថ្ងៃទី ២៦-៨-២០១៣

## សាលាឧទ្ធរណ៍ភ្នំពេញ

បានបញ្ចប់ការទាញហេតុផលផ្ទាល់មាត់នាថ្ងៃ ២៦ ខែសីហា ឆ្នាំ២០១៣

### ក្រុមប្រឹក្សា

លោក [redacted] ជាប្រធាន
លោក [redacted] ចៅក្រមប្រឹក្សា
លោក [redacted] ចៅក្រមប្រឹក្សា

### ក្រឡាបញ្ជី

លោក [redacted]

១-ដើមចោទឈ្មោះ [redacted] ដាត ភេទប្រុស អាយុ៤៩ឆ្នាំ លំនៅឋានសព្វថ្ងៃភូមិជ័យជំនះ សង្កាត់ ឡាបានសៀក ក្រុងបានលុង ខេត្តរតនគិរី ប្រពន្ធឈ្មោះ [redacted] សំ មានកូន៣នាក់ ។

២-ដើមចោទឈ្មោះ [redacted] ហ្សាគី ភេទប្រុស អាយុ៤១ឆ្នាំ លំនៅឋានសព្វថ្ងៃភូមិ៣ សង្កាត់ ឡាបាន សៀក ក្រុងបានលុង ខេត្តរតនគិរី ។

៣-ដើមចោទឈ្មោះ [redacted] រ៉នី ភេទប្រុស អាយុ៣៣ឆ្នាំ លំនៅឋានសព្វថ្ងៃភូមិ៣ សង្កាត់ឡាបាន សៀក ក្រុងបានលុង ខេត្តរតនគិរី ។

៤-ដើមចោទឈ្មោះ [redacted] នូរី ភេទប្រុស អាយុ២៥ឆ្នាំ លំនៅឋានសព្វថ្ងៃភូមិ១ សង្កាត់ឡាបាន សៀក ក្រុងបានលុង ខេត្តរតនគិរី (នៅលីវ) ។

-លោក [redacted] មជាវិតំណាងដោយអាណត្តិ ។

១-ចុងចម្លើយឈ្មោះ [redacted] រ៉ម៉ាស់ (ហៅជុ) ភេទស្រី អាយុ៥៦ឆ្នាំ លំនៅឋានសព្វថ្ងៃភូមិ៣ សង្កាត់ ឡាបានសៀក ក្រុងបានលុង ខេត្តរតនគិរី ប្តីឈ្មោះ [redacted] ឡេះ "ស" មានកូន៤នាក់ ។

-លោក [redacted] មេធាវីតំណាងដោយអាណត្តិ ។

### ខ្លឹមសារនៃការទាមទារ

១-ការទាមទាររបស់ដើមចោទ:

-ទាមទារបែងចែកមរតកដីទំហំ ២៧ម×៦៨ម ស្ថិតនៅភូមិ៣ សង្កាត់ឡាបានសៀក ក្រុងបាន លុង ខេត្តរតនគិរី ។





Scanned with CamScanner

## អំពីអង្គហេតុ និងចំណុចខុសខាង

ដើមចោទប្តឹងសុំអោយតុលាការចេញសាលក្រមបង្គាប់អោយចុងចម្លើយឈ្មោះ [redacted] រ៉ម៉ាស់ បែង ចែកបេតិកភណ្ឌរបស់សពឪពុកឈ្មោះ [redacted] ឡែះ ដីទំហំ ២៧ម×៦៨ម ដែលមានសំណង់ផ្ទះ និងសំណង់ បន្ទប់ជួលចំនួន២៣បន្ទប់ ស្ថិតនៅភូមិ៧មករា(អតីតភូមិ៣) សង្កាត់ឡាបានសៀក ក្រុងបានលុង ខេត្ត រតនគិរី ។

## នាពេលសវនាការ

-ដើមចោទឈ្មោះ [redacted] ហ្សាកី (វត្តមាន)
-ដើមចោទឈ្មោះ [redacted] ដាត (អវត្តមាន)
-ដើមចោទឈ្មោះ [redacted] រ៉ឌី (វត្តមាន)
-ដើមចោទឈ្មោះ [redacted] នូរី (អវត្តមាន)
-លោក [redacted] មេធាវីតំណាងដើមចោទ (វត្តមាន)
-ចុងចម្លើយឈ្មោះ [redacted] រ៉ម៉ាស់(ហៅជុ) (អវត្តមាន)
-លោក [redacted] មេធាវីតំណាងចុងចម្លើយ (វត្តមាន)

-លោក [redacted] មេធាវីតំណាងដោយអាណត្តិអោយចុងចម្លើយបានធ្វើសេចក្តីថ្លែងការណ៍ថា ក្នុងរឿងក្តីនេះ កូនក្តីខ្លួនមិនសុខចិត្តនឹងសាលក្រមសាលាដំបូងខេត្តរតនគិរី ព្រោះសាលាដំបូងមិនបានពិចារណាលើទ្រព្យអកម្ម ហើយកូនក្តីខ្លួនបានជំពាក់បំណុលគេច្រើន ដូចគាត់អះអាងនៅពេលត្រៀមទាញហេតុផល និងមានឯកសារភស្តុតាងភ្ជាប់មកជាមួយ ចំពោះដើមចោទឈ្មោះ [redacted] ដាត និងឈ្មោះ [redacted] ហ្សាកី ក៏បានទទួលមរតកលំនៅដ្ឋានរបស់សព [redacted] ឡែះ រួចហើយ ដូចនេះសូមក្រុមប្រឹក្សាពិចារណា លើមាត្រា១២៨៣ និងមាត្រា១២៨៨ នៃក្រមរដ្ឋប្បវេណី តាងនាមខ្លួនជាមេធាវីតំណាងចុងចម្លើយ សូមក្រុមប្រឹក្សាបដិសេធ សាលក្រមរដ្ឋប្បវេណីលេខ ០១ "ខ" ចុះថ្ងៃ ១៧-៥-២០១៣ របស់សាលាដំបូងខេត្តរតនគិរី ។

-លោក [redacted] មេធាវីតំណាងដោយអាណត្តិអោយដើមចោទ បានធ្វើសេចក្តីថ្លែងការណ៍ថា ក្នុងនីតិវិធីក្រមរដ្ឋប្បវេណី ចុងចម្លើយមិនបានប្តឹងតបទៅសាលាដំបូងទេ រីឯទ្រព្យមរតកគឺសាលាដំបូងខេត្តរតនគិរី បានបែងចែកអោយចុងចម្លើយច្រើនណាស់ហើយ ។ សំណូមពរ សូមក្រុមប្រឹក្សាតម្កល់សាលក្រមលេខ ០១ "ខ" ចុះថ្ងៃ ១៧-៥-២០១៣ របស់សាលាដំបូងខេត្តរតនគិរី ទុកជាបានការដដែល ។

## សំអាងហេតុ

យល់ឃើញថា :

១-បណ្តឹងឧទ្ធរណ៍លេខ ០៦ ចុះថ្ងៃ ២៩-៥-២០១៣ របស់ឈ្មោះ [redacted] រ៉ម៉ាស់ ធ្វើឡើងក្នុងកំណត់ច្បាប់យោងតាមមាត្រា២៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី សាលាឧទ្ធរណ៍ទទួលជំនុំជម្រះបាន។

-មេធាវី [redacted] តំណាងដោយអាណត្តិអោយដើមចោទ

-មេធាវី [redacted] តំណាងដោយអាណត្តិអោយចុងចម្លើយឈ្មោះ [redacted] រ៉ម៉ាស់ សុំលើកពេលទាញហេតុផលផ្ទាល់មាត់នៅថ្ងៃ ២៦-៨-២០១៣ ដោយលើកហេតុថា កូនក្តីទើបពឹងពាក់ និង

ពុំទាន់បានសិក្សាសំណុំរឿងក្តី ។ ក្រុមប្រឹក្សាយល់ថា មេធាវីបានដាក់ពាក្យ សុំទទួលស្គាល់មេធាវី នៅថ្ងៃ ១៣-៨-២០១៣ និងសុំថតចម្លងសំណុំរឿង ហើយក្រឡាបញ្ជីបានថត ចម្លងជូនរួចហើយ ក្រុមប្រឹក្សា មិនអាចអនុញ្ញាត ។

២-តាមចុងចម្លើយឈ្មោះ [redacted] រ៉ម៉ាស់ បានឆ្លើយថា បានរៀបការតាមសាសនាអ៊ីស្លាម ជាមួយឈ្មោះ [redacted] ឡេះ កាលពីខែកក្កដា ឆ្នាំ១៩៨៧ នៅឃុំក្រគរ ស្រុក-ខេត្តក្រចេះ ។ ពេលនោះខ្លួនដឹងថាប្តីឈ្មោះ [redacted] ឡេះ ពោះម៉ាយ ។ បីឆ្នាំក្រោយមកទើបដឹងថា ប្តីឈ្មោះ [redacted] ឡេះ មានកូន៤នាក់ ឈ្មោះ [redacted] ត ភេទប្រុស,ឈ្មោះ [redacted] ហ្សាគី ភេទប្រុស ឈ្មោះ [redacted] រ៉នី ភេទប្រុស និងឈ្មោះ [redacted] នូរី ភេទប្រុស ។ ក្នុងការរួមរស់នៅជាមួយឈ្មោះ [redacted] ឡេះ និងរូបខ្លួនមានកូន៣នាក់ ឈ្មោះ [redacted] រ៉ស្រាក់ ភេទប្រុស,ឈ្មោះ [redacted] ឧសភា ភេទប្រុស និងឈ្មោះ [redacted] ធារី ភេទស្រី ។ ឯឈ្មោះ [redacted] សេងហុង ភេទប្រុស ជាកូនរបស់ខ្លួនដែរ (កូនប្តីមុន) ។ ឈ្មោះ [redacted] ឡេះ ស្លាប់ នៅថ្ងៃ ២០ ខែសីហា ឆ្នាំ២០១២ ។ ដូចនេះ ចុងចម្លើយឈ្មោះ [redacted] រ៉ម៉ាស់ ជាសហព័ទ្ធរបស់មតកជន និងជាសន្តតិជនជានិច្ចតាមមាត្រា ១១៦១ នៃក្រមរដ្ឋប្បវេណី ។ ចំណែកកូនទាំង៨នាក់ ក៏ជាសន្តតិជនរបស់មតកជនឈ្មោះ ហ៊ីម ឡេះ ដែរ ដែលត្រូវបានទទួលចំណែកមរតកស្មើគ្នា តាមមាត្រា១១៦២ នៃក្រមរដ្ឋប្បវេណី ។

តាមការអះអាងរបស់ចុងចម្លើយ នៅដំណាក់កាលនីតិវិធីត្រៀមលើកទី១ (ឯ.១១)ថា មានជំពាក់បំណុលធនាគារអេស៊ីលីដា ៤០០០$ លោកជំទាវ [redacted] សារុន ៨០០$ ចៃស្រីនៅអាមេរិក ៥០០$ ឈ្មោះ ឡែន នៅភ្នំពេញ ៨០០០$ ជំពាក់ថ្លៃដីដាំកៅស៊ូ ៦២៥០$ តាគុយទាវហោះ ៣០០$ យាយវែង ១៧០$ ឈ្មោះ [redacted] អ៊ិន ១៧០០$ ឈ្មោះ [redacted] ម៉ាក់ ២៥០$ និងមួយចំនួនទៀត ។

ក្នុងការព្យាបាលជម្ងឺ ហ៊ីម ឡេះ នៅមន្ទីរពេទ្យខ្លួនបានចំណាយប្រាក់ ១៧០៥៧ដុល្លា និងចំណាយធ្វើបុណ្យសពសអស់ ១៤៦០ដុល្លា ។ ឃើញថា ចុងចម្លើយមានជំពាក់បំណុលអ្នកដទៃច្រើនចំណាយព្យាបាលជម្ងឺ និងធ្វើបុណ្យសព អស់ច្រើនតែចុងចម្លើយពុំមានភស្តុតាង ជាលាយល័ក្ខអក្សរដាក់នៅសាលាដំបូងទេ ។ ដូចនេះ សាលាឧទ្ធរណ៍មិនអាចពិចារណាបានឡើយ ។

៤-ដីលំនៅដ្ឋានទំហំ ១៨០៣ម² មានសំណង់ផ្ទះទំហំ១៣៨ម² មានសំណង់បន្ទប់ចំនួន២៣បន្ទប់តាមគំនូសបង្ហាញទីតាំងដី ចុះថ្ងៃ ២៥ ខែមេសា ឆ្នាំ២០១៣ របស់មន្ទីររៀបចំដែនដីនគរូបនីយកម្មសំណង់ ខេត្តរតនគិរី ជាទ្រព្យសហកម្មសិទ្ធិរបស់ឈ្មោះ [redacted] ឡេះ និងឈ្មោះ [redacted] រ៉ម៉ាស់ គប្បីបែងចែកអោយឈ្មោះ [redacted] រ៉ម៉ាស់ ពាក់កណ្តាលនិងពាក់កណ្តាលទៀតជាមរតករបស់មតកជន [redacted] ឡេះ ត្រូវបែងចែកដល់កូនប្រាំបីនាក់ និងឈ្មោះ [redacted] រ៉ម៉ាស់ នូវចំណែកស្មើគ្នា ។

៥-សាលក្រមរដ្ឋប្បវេណីលេខ ០១ "ខ" ចុះថ្ងៃ ១៧-៥-២០១៣ របស់សាលាដំបូងខេត្តរតនគិរី ត្រឹមត្រូវ ហើយគួរតម្កល់ទុកជាបានការ ។

## ហេតុដូច្នេះវិនិច្ឆ័យសេចក្ត

១-ច្រានចោលបណ្តឹងឧទ្ធរណ៍លេខ ០៦ ចុះថ្ងៃ ២៩-៥-២០១៣ របស់ឈ្មោះ [redacted] រ៉ម៉ាស់។

២-តម្កល់សាលក្រមរដ្ឋប្បវេណីលេខ ០១ "ខ" ចុះថ្ងៃ ១៧-៥-២០១៣ របស់សាលាដំបូងខេត្តរតនគិរី ទុកជាបានការ ។

៣-ប្រាក់ប្រដាប់ក្តីជាបន្ទុកចុងចម្លើយ

៤-សាលដីកានេះ បញ្ចប់ការទាញហេតុផលផ្ទាល់មាត់ និងប្រកាសជាសាធារណៈ បើកសិទ្ធិប្តឹងសាទុក្ខរយៈពេល១ខែ គិតពីថ្ងៃបានទទួលការបញ្ជូនសាលដីកានេះ ។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|

ហត្ថលេខា [redacted]

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

ភ្នំពេញ,ថ្ងៃទី៨ ខែ៧ ឆ្នាំ២០១៣

ក្រឡាបញ្ជី

[redacted]

បានឃើញ

ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

[redacted]



Scanned with CamScanner